# ការជូនដំណឹងរបស់តុលាការ (Judicial Notice) (Oscar B. Bernardo, Evidence annotated, 2011, ទំ. ១១ ដល់ ២១)

**ពាក្យគន្លឹះ÷** ការកត់សំគាល់របស់តុលាការ (judicial notice: JN) ការទទួលយក និងការបដិសេធ

**១.** ក្នុងការចោទប្រកាន់រឿងព្រហ្មទណ្ឌ មានភស្តុតាងជាច្រើនប្រភេទ អាចជាព័ត៌មានទទួលបានតាមវិធីសាស្រ្តស៊ើបអង្កេតបែបវិទ្យាសាស្រ្ត (scientific evidence) ឬព័ត៌មានទូទៅ ដូចជាច្បាប់ ឬព័ត៌មានស្តីពីការងាររដ្ឋបាល។ ព័ត៌មានទាំងនោះ ត្រូវបានទទួលយកដោយតុលាការ ដោយមាន ឬគ្មានការពិភាក្សាដេញដោល (hearing)។ នេះជា ការកត់សំគាល់របស់តុលាការ (judicial notice)។ ព័ត៌មានប្រភេទនេះ មានដូចជា ច្បាប់ ការដឹក នាំរដ្ឋ... ដែលអាចចាត់ជាប្រភេទត្រូវតែទទួលយក (mandatory) មិនចាំបាច់ឆ្លងកាត់ការដេញដោល ឬ អាចឆ្លងកាត់ការដេញដោល (discretionary judicial notice)។

**២.** ផ្នែកទី១វិធានទី១២៩ ក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសហ្វីលីពីនចែង÷ *តុលាការត្រូវទទួលយកការកត់សំគាល់ ដោយគ្មានណែនាំភស្តុតាង នូវអត្ថិភាពនិងវិសាលភាពដែនដីនៃរដ្ឋ ប្រវត្តិ នយោបាយ ទម្រង់នៃរដ្ឋាភិបាលនិងអត្តសញ្ញាសញ្ជាតិ ច្បាប់ជាតិ តុលាការសមុទ្រនៃពិភពលោកនិងត្រា រដ្ឋធម្មនុញ្ញនិងប្រវត្តិនៃប្រទេសហ្វីលីពីន កិច្ចផ្លូវការរបស់សភា ផ្នែកតុលាការនិងនីតិប្រតិបត្តិនៃប្រទេសហ្វីលីពីន ច្បាប់ធម្មជាតិ ការវាស់វែងពេលវេលា និងការបែងចែកភូមិសាស្រ្ត។*[1]

**៣.** ការធ្វើដូចនេះ ដើម្បីកាត់បន្ថយពេលវេលានៃនីតិវិធីតុលាការ។ ដើម្បីទទួលយកនូវការកត់សំគាល់ (mandatory) លក្ខខណ្ឌចំនួនបីត្រូវបំពេញ÷ ក. ចំណេះដឹងទូទៅ។ **ខ.** មានភាពច្បាស់លាស់ គ្មានមន្ទិលនិង **គ.** ស្ថិតនៅក្នុងកម្រិតយុត្តាធិការរបស់តុលាការ។ ចំណេះដឹងផ្ទាល់របស់ចៅក្រម មិនមែនជា

[1] Judicial notice, when mandatory.-A court shall take judicial notice, without the introduction of evidence, of the existence and territorial extent of states, their political history, forms of governments and symbols of nationality, the law of nations, the admiralty and maritime courts of the world and their seals, the political constitution and history of the Philippines, the official acts of the legislative, executive and judicial departments of the Philippines, the laws of nature, the measure of time, and the geographical divisions.

របស់តុលាការទេ (មិនមែនជា judicial notice)។ សម្រាប់ការទទួលយក JN ជាឆន្ទានុសិទ្ធិ (អាចឆ្លងកាត់ការដេញដោល) ក៏ត្រូវបំពេញលក្ខខណ្ឌចំនួនបីផងដែរ÷ **ក.** ចំណេះដឹងសាធារណៈ។ **ខ.** បញ្ហាមិនមានចំណោទត្រូវសាកសួរ (matters capable of unquestionable demonstration) និង **គ.** បញ្ហាត្រូវបានដឹងដោយសារតួនាទីជាចៅក្រម។ ច្បាប់បរទេស ជាវិស័យ (matter) មួយក្នុងនេះ មិនចូលក្នុង JN ទេដោយសារ ច្បាប់នេះ ត្រូវតែបានលើកឡើង និងអះអាងគាំទ្រ។ ដូចគ្នានេះដែរ តុលាការមិនអាចកត់សំគាល់នូវការស្លាប់របស់ចុងចម្លើយ ដោយគ្មានការពន្យល់របស់មេធាវីភាគីចុងចម្លើយ។

**៤.** ការទទួលយក JN ត្រូវបានធ្វើឡើងក្នុងនីតិវិធីនៃសំណុំរឿងកំពង់ដំណើរការ តាមរយៈការដាក់ញត្តិ។ ការទទួលយកត្រូវបានសន្មតថាមានការយល់ព្រម និងមិនតម្រូវឲ្យមានបង្ហាញនូវភស្តុតាងគាំទ្រទេ។ ការទទួលយករបស់មេធាវី ចងដល់អចិតិជនរបស់គាត់។ ទោះបីជាយ៉ាងនេះក្តី ការទទួលយកនេះ ក្រោយមកអាចត្រូវបដិសេធវិញ ដោយសារមូលហេតុនៃការច្រឡំ។ ការបដិសេធ ត្រូវតែធ្វើឡើងឲ្យទាន់ពេលវេលាកំណត់ក្នុងនីតិវិធី។